# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៤០

## ស្តីពី

## ការបង្កើតសហគមន៍នេសាទ

៚

### យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា ១.–**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ខ្លួន តាមរយៈការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ។

**មាត្រា ២.–**

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា ៣.–**

សហគមន៍នេសាទដែលមានដែននេសាទជាប់គ្នា អាចចូលរួមជាមួយគ្នាដោយបង្កើតជាសហព័ន្ធសហគមន៍នេសាទបាន។

វិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.–**

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩រ.០៥០៥.២៥៥

**បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ**

**ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ២១៥ - ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**